ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៦៦ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៣៥ សហវ.ប្រក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការបង្កើតមូលនិធិ-អភិវឌ្ឍន៍សហគ្រិនភាព
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការបំពេញការងាររបស់លេខាធិការដ្ឋានមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព(**ម.អ.ស.**)។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់អំពីភារកិច្ច និងមុខងាររបស់លេខាធិការដ្ឋាន **ម.អ.ស.**។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាព អនុវត្តចំពោះអង្គភាពក្រោមឱវាទលេខាធិការដ្ឋាន **ម.អ.ស.**។

## ជំពូកទី២

## រចនាសម្ព័ន្ធ

**ប្រការ៤.-**

លេខាធិការដ្ឋាន **ម.អ.ស.** ត្រូវដឹកនាំដោយប្រធាន ០១ រូប និងមានអនុប្រធាន ០១ រូប ជាសេនាធិការ។ សមាសភាពជាក់ស្តែងនៃប្រធាន អនុប្រធាន និងសមាជិករបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៥.-**

លេខាធិការដ្ឋានមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព មានរចនាសម្ព័ន្ធដូចខាងក្រោម÷

- ផ្នែកកិច្ចការទូទៅ និងហិរញ្ញវត្ថុ
- ផ្នែកត្រួតពិនិត្យ និងវាយតម្លៃថវិកាកម្មវិធី
- ផ្នែកវិភាគ និងត្រួតពិនិត្យគម្រោងវិនិយោគ
- មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ រូប និងមានមន្ត្រីមួយចំនួនតាមការចាំបាច់។

មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព ត្រូវដឹកនាំដោយនាយកប្រតិបត្តិ ០១ រូប ដែលត្រូវតែងតាំង និងផ្លាស់ប្តូរដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ម.អ.ស.**។

**ប្រការ៦.-**

អង្គការលេខរបស់មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៣
## ភារកិច្ច និងមុខងារ

**ប្រការ៧.-**

ផ្នែកកិច្ចការទូទៅ និងហិរញ្ញវត្ថុ មានភារកិច្ចដូចខាងក្រោម÷

- បូកសរុប និងរៀបចំផែនការថវិការបស់មូលនិធិអភិវឌ្ឍន៍សហគ្រិនភាពដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាល **ម.អ.ស.** ពិនិត្យ និងសម្រេច,
- បូកសរុប និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ **ម.អ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាល ពិនិត្យ និងសម្រេច,
- សម្របសម្រួល និងគ្រប់គ្រងការងារសវនកម្មដោយសវនករឯករាជ្យ,
- រៀបចំ និងកត់ត្រាកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាបរធនបាល **ម.អ.ស.**,
- គ្រប់គ្រង និងតាមដានការងាររដ្ឋបាល និងបុគ្គលិករបស់លេខាធិការដ្ឋាន **ម.អ.ស.** និង
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំ។

**ប្រការ៨.-**

ផ្នែកត្រួតពិនិត្យ និងវាយតម្លៃថវិកាកម្មវិធី មានភារកិច្ចដូចខាងក្រោម÷

- ពិនិត្យ ផែនការសកម្មភាពប្រចាំឆ្នាំរបស់ **ម.អ.ស.** និងមជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព ដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាល **ម.អ.ស.** ពិនិត្យ និងសម្រេច,
- តាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងសូចនាករសមិទ្ធផលប្រចាំឆ្នាំ,
- ពិនិត្យរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលការងារប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាល **ម.អ.ស.** ពិនិត្យ និងផ្តល់ការណែនាំ និង
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំ។

**ប្រការ៩.-**

ផ្នែកវិភាគ និងត្រួតពិនិត្យគម្រោងវិនិយោគ មានភារកិច្ចដូចខាងក្រោម÷

- ពិនិត្យផែនការវិនិយោគ **ម.អ.ស.** តាមសំណើរបស់មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព,
- វិភាគ, ពិនិត្យ និងផ្តល់អនុសាសន៍លើសំណើវិនិយោគរបស់មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព,
- រៀបចំបញ្ជីសារពើភ័ណ្ឌ ចំណែកភាគហ៊ុន និងសំណើវិនិយោគដែលបានអនុម័ត,
- តាមដានត្រួតពិនិត្យ និងរៀបចំរបាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ និង
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំ។

**ប្រការ១០.-**

មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព សរសេរកាត់ថា **ម.ល.ស.** និងមានឈ្មោះជាភាសាអង់គ្លេសថា

"Entrepreneurship Promotion Center" ដែលសរសេរជាអក្សរកាត់ថា "EPC" ត្រូវមានស្វ័យភាពរដ្ឋបាលក្នុងការគ្រប់គ្រងប្រតិបត្តិការ និងមានភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ, ផែនការថវិកាប្រចាំឆ្នាំ, ផែនការវិនិយោគ និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីដាក់មកលេខាធិការដ្ឋាន **ម.អ.ស.** ពិនិត្យ និងផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សាបរធនបាល **ម.អ.ស.** ពិនិត្យ និងអនុម័ត,
- រៀបចំបទបញ្ជាផ្ទៃក្នុង និងរចនាសម្ព័ន្ធ **ម.ល.ស.** ដែលមានផ្នែកគ្រប់គ្រងការងារបច្ចេកទេសស្នូលមួយចំនួន ដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាល **ម.អ.ស.** ពិនិត្យ និងអនុម័ត,
- រៀបចំភារកិច្ច និងក្របខ័ណ្ឌលទ្ធផលការងារដោយភ្ជាប់នឹងសូចនាករសមិទ្ធិផលរបស់ផ្នែកបច្ចេកទេសនីមួយៗស្របតាមរចនាសម្ព័ន្ធដែលបានអនុម័តរួច,
- រៀបចំរបាយការណ៍វឌ្ឍនភាព និងលទ្ធផលការងារប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់មកលេខាធិការដ្ឋាន **ម.អ.ស.** បូកសរុប និង
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ក្រុមប្រឹក្សាបរធនបាល **ម.អ.ស.**។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចប្រការ១២
- រាជកិច្ច

ឧបសម្ព័ន្ធនៃប្រកាសលេខ...........ថ្ងៃទី..........ខែ..........ឆ្នាំ២០១៩

**អង្គការលេខរបស់**

**មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព**

